# LANGUAGE RIGHTS

## Voter Hotline: 1-888-API-VOTE




# អ្នកមានសិទ្ធិទទួលការជួយនៅក្នុងបន្ទប់បោះឆ្នោតបាន

**ខ្ញុំមិនមានអារម្មណ៍ល្អសោះក្នុងការបោះឆ្នោតម្នាក់អែង ។ តើខ្ញុំអាចនាំមនុស្សម្នាក់មកជាមួយក្នុងបន្ទប់ដើម្បីជួយខ្ញុំបោះឆ្នោតបានឬទេ ?**

បាន ។ អ្នកមានសិទ្ធិនាំនរណាម្នាក់មកជួយក្នុងបន្ទប់បោះឆ្នោតបាន ។ មនុស្សម្នាក់នេះអាចជាមិត្តសំឡាញ់ ញាតិ ឬ នរណាម្នាក់ដែលអ្នកទុកចិត្ត ។ តែមិនអាចជា ចៅហ្វាយរបស់អ្នក ឬ

**តំណាងសហភាពការងាររបស់អ្នកទេ ។ តើច្បាប់អ្វីដែលឲ្យសិទ្ធិនេះដល់ខ្ញុំ ?**

មាត្រា ២០៨ នៃសេចក្ដីសម្រេចលើសិទ្ធិបោះឆ្នោត (VRA) អោយសិទ្ធិដល់អ្នកបោះឆ្នោត ដើម្បីនាំនរណាម្នាក់តាមចំណូលចិត្តមកក្នុងបន្ទប់ប្រសិនបើត្រូវការជំនួយក្នុងការបោះឆ្នោត ។

**តើធ្វើដូចម្ដេចឲ្យខ្ញុំដឹងថាខ្ញុំអាចទទួលផលប្រយោជន៍ពីច្បាប់នេះ ?**

បើសិនជាភាសាកំណើតរបស់អ្នកមិនមែនជាភាសាអង់គ្លេស ហើយអ្នកមានការពិបាកនឹង យល់ភាសាអង់គ្លេស អ្នកអាចប្រើច្បាប់នេះបាន ។ អ្នកអាចប្រើច្បាប់នេះបានដែរបើសិនជាអ្នកខ្វាក់ភ្នែក ឬ មើលមិនច្បាស់ មានភាពពិការ ឬ មានបញ្ហាក្នុងការអាន ឬ សរសេរអក្សរ ។

**តើខ្ញុំត្រូវការធ្វើអ្វីខ្លះនៅថ្ងៃបោះឆ្នោតដើម្បីឲ្យមានអ្នមកជួយខ្ញុំក្នុងការបោះឆ្នោត?**

ចូរនាំមនុស្សដែលនឹងជួយអ្នកទៅកន្លែងបោះឆ្នោត ។ ចូរប្រាប់អ្នកមានសមត្ថកិច្ចជាផ្លូវការ ថាអ្នកបានរើសមនុស្សនេះដើម្បីជួយខ្ញុំបោះឆ្នោត ។ អ្នកប្រហែលជាត្រូវ បំពេញលិខិត និង ចុះហត្ថលេខាដែលចែងថាអ្នកមានការពិបាកក្នុងការនិយាយ ការអាន ការសរសេរ ឬ ការយល់ភាសាអង់គ្លេស ទើបបានសូមឲ្យមនុស្សម្នាក់នេះជួយ ។ មនុស្សដែលជួយអ្នកក៏អាចនឹងត្រូវចុះហត្ថលេខាលើលិខិតមួយដោយស្បថថាគាត់ មិនបានប្រាប់អ្នកថាតើនឹងបោះឆ្នោតយ៉ាងដូចម្ដេច ។

**តើខ្ញុំត្រូវខ្លះធ្វើអ្វីបើសិនជាគេមិនអនុញ្ញាត្តឲ្យខ្ញុំនាំនរណាម្នាក់មកជាមួយចូលក្នុងបន្ទប់បោះ ឆ្នោត?**

អ្នកមានសមត្ថកិច្ចរៀបចំបោះឆ្នោតខ្លះមិនដឹងអំពីមាត្រា ២០៨ នៃ VRA ទេ ។ បើអ្នកនាំមនុស្សម្នាក់មកជួយអ្នក ហើយអ្នកមានសមត្ថកិច្ចនោះមិនព្រមអនុញ្ញាត្តឲ្យគាត់ជួយអ្នក ចូរអ្នកបង្ហាញខិត្តប័ណ្ណនេះទៅអ្នកមានសមត្ថកិច្ចភ្លាម ។ បើអ្នកមានសមត្ថកិច្ចបោះឆ្នោតនោះនៅតែមិនព្រមឲ្យគេជួយអ្នកទៀត ចូរទៅនិយាយជាមួយនឹងអាជ្ញាធរជាន់ខ្ពស់បំផុតនៅកន្លែងបោះឆ្នោតនោះ ឬ ចូរទូរស័ព្ទទៅជំនួយបន្ទាន់ ១-៨៨៨-**API-VOTE** ។

### តើអ្នកបានដឹងឬទេ ?

- អ្នកអាចនាំសមាជិកគ្រួសារ អ្នកជិតខាង --- ស្មើរតែអស់អ្នកណាដែលអ្នកទុកចិត្តនៅក្នុង សហគមន៍ --- ដើម្បីនឹងជួយអ្នកក្នុងការបោះឆ្នោត ។

**១-៨៨៨-API-VOTE: ចូរទូរស័ព្ទសុំជំនួយភាសា ខ្មែរ នៅថ្ងៃបោះឆ្នោត។**

សំរាប់ពត៏មានបន្ថែមអំពីចូលរួមបោះឆ្នោតចំពោះអ្នកបោះដែលនិយាយភាសាអង់គ្លេសមិនព េញលេញ សូមអញ្ជើញចូលទៅ:

www.advancingjustice-aajc.org/language-rights.